SBI Bank (Cambodia)

លក្ខខណ្ឌទូទៅនៃកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)

រៀបរៀងដោយ៖ នាយកដ្ឋានធនាគារឌីជីថល

មាតិកា

និយមន័យ 1
១. សេចក្តីណែនាំ 3
២. លក្ខខណ្ឌសម្រាប់អ្នកប្រើប្រាស់ 3
៣. ការបង្កើតគណនីកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) 4
៤. គោលការណ៍ឯកជនភាព 4
៥. សកម្មភាពហាមឃាត់ 4
៦. ការពិពណ៌នាអំពីសេវាកម្ម 5
៧. ព័ត៌មានអំពីគណនី 5
៨. កម្រិតនៃសេវាកម្ម 7
៩. កម្រៃសេវាកម្ម និងការចំណាយផ្សេងៗ 8
១០. រូបិយប័ណ្ណ 8
១១. សុវត្ថិភាពលេខកូដសម្ងាត់ 8
១២. ការកែប្រែនៃលក្ខខណ្ឌទូទៅ និងនៃកម្រៃសេវាកម្ម និងចំណាយផ្សេងៗ 9
១៣. ការការពារការសម្អាតប្រាក់ និងបទល្មើសផ្សេងៗ 10
១៤. ការបដិសេធមិនផ្តល់សេវាកម្ម 10
១៥. ការបញ្ចប់ការព្រមព្រៀង 11
១៦. ការធានាសំណង 11
១៧. ការបង្ហាញព័ត៌មានដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា) 11
១៨. ការផ្លាស់ប្តូរលក្ខខណ្ឌទូទៅ 12
១៩. អសង្គតិភាព 12
២០. ការជូនដំណឹងក្នុងកម្មវិធី 12
២១. កាតព្វកិច្ចរបស់អ្នកប្រើប្រាស់ 12
២២. វិវាទ និងយន្តការដោះស្រាយ 13
២៣. វិវាទជាមួយតតិយជន 13
២៤. ទំនាក់ទំនង 13
ឧបសម្ព័ន្ធទី១ 14
ឧបសម្ព័ន្ធទី២ 15

និយមន័យ

និយមន័យនៃវាក្យស័ព្ទនីមួយៗដែលផ្តល់ជូនក្នុងលក្ខខណ្ឌទូទៅនេះ ត្រូវយកមកអនុវត្ត លើកលែងតែមានការចែងផ្ទុយពីនេះ៖	
ធនាគារចល័តរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)	សំដៅដល់កម្មវិធីលើទូរស័ព្ទដៃមួយ ដែលលោកអ្នកអាចទាញយកបានដោយខ្លួនឯងតាមរយៈ App Store ឬ Google Play Store និង AppGallery។ ការផ្តល់សេវាកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិច (ឧបករណ៍តាមការជ្រើសរើសរបស់លោកអ្នក ឬទូរស័ព្ទដៃ) ដើម្បីភ្ជាប់ទៅកាន់គណនីធនាគារតាមរយៈកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)។
គណនី	សំដៅដល់គណនី និងមានរួមបញ្ចូលដូចជា គណនីសន្សំរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) គណនីបញ្ញើមានកាលកំណត់ ទាំងលើរូបិយបណ្ណ រៀល និងដុល្លារ ដែលត្រូវបានបង្កើតក្នុងពេលជាក់លាក់ណាមួយនៅតាមបណ្តាសាខារបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ឬតាមរយៈធនាគារចល័តរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)។
ម្ចាស់គណនី	សំដៅដល់បុគ្គល ឬនីតិបុគ្គល ដែលបានបង្កើតឡើងដោយមានឈ្មោះក្នុងគណនីរបស់ខ្លួន ហើយជាអ្នកដែលទទួលខុសត្រូវ និងគ្រប់គ្រងទៅលើប្រតិបត្តិការក្នុងគណនីនោះ។
កូដផ្ទៀងផ្ទាត់	សំដៅដល់លេខដែលត្រូវបានបង្កើតឡើងដោយចៃដន្យតាមរយៈឧបករណ៍សុវត្ថិភាព ឬលេខកូដសម្ងាត់ SMS One Time Password ដោយប្រព័ន្ធរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលប្រើបានតែម្តងប៉ុណ្ណោះ។
ប្រតិបត្តិករ	សំដៅដល់ស្ថាប័នមួយស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានបើកគណនីជាមួយធនាគារ អេស ប៊ី អាយ (ខេមបូឌា) និងបានចុះឈ្មោះជាមួយធនាគារ ដើម្បីទទួលបានការទូទាត់ពីអតិថិជនរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) តាមរយៈបណ្តាញធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)។
ការទូទាត់វិក្កយបត្រ	គឺជាមុខងារមួយដែលអាចរកបាននៅលើសេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ហើយអនុញ្ញាតឲ្យលោកអ្នកអាចធ្វើការទូទាត់ពីគណនីធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលបានភ្ជាប់នៅនឹងគណនី ដែលបានបើក និងប្រើប្រាស់ ទៅកាន់ប្រតិបត្តិករដែលត្រូវទូទាត់របស់លោកអ្នក។
ឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ	រួមមាន ស្នាមម្រាមដៃ ទិន្នន័យមុខ និងទិន្នន័យផ្សេងៗទៀត ដែលក្រុមហ៊ុនផលិតឧបករណ៍ចល័តអនុញ្ញាតឲ្យអ្នកប្រើប្រាស់ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេក្នុងគោលបំណងបើកសោលើឧបករណ៍ចល័ត និងចូលប្រើប្រាស់កម្មវិធីជាក់លាក់មួយ ដែលក្នុងនោះមាន ធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ផងដែរ។
បណ្ណ	សំដៅដល់បំណុលឥណពន្ធ/បណ្ណឥណទានរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ជាមួយនឹងគម្រោងបណ្ណវីសា (VISA) ក្នុងទម្រង់ជាបណ្ណនិម្មិត ឬបណ្ណផ្លាស្ទិក។
លេខ CIF	គឺជាលេខពិសេសមួយសម្រាប់សម្គាល់អត្តសញ្ញាណអតិថិជន ត្រូវបានប្រើប្រាស់នៅក្នុងប្រព័ន្ធរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលលោកអ្នកទទួលបាននៅក្នុងអំឡុងពេលដែលមានការចុះឈ្មោះបើកគណនីដំបូងរបស់លោកអ្នកជាមួយនឹងធនាគារ។
អតិថិជន	រួមមាន ម្ចាស់គណនីធនាគារ អេស ប៊ី អាយ (ខេមបូឌា) និងមិនមែនម្ចាស់គណនីធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលប្រើប្រាស់សេវាកម្មធនាគារម្តងម្កាលពីធនាគារ អេស ប៊ី អាយ (ខេមបូឌា) ។ អតិថិជនទាំងអស់ត្រូវទទួលបានការអង្កេត និងវាយតម្លៃក្នុងទម្រង់ផ្សេងៗគ្នា។
របាយការណ៍គណនីអេឡិចត្រូនិច(e-Statement)	គឺជារបាយការណ៍ធនាគាររួមមួយ ដែលឆ្លុះបញ្ចាំងអំពីកំណត់ត្រាក្នុងអំឡុងពេលជាក់លាក់ណាមួយរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) សម្រាប់គណនីរបស់អតិថិជននៅលើធនាគារចល័ត របស់

	ធនាគារ អេស ប៊ី អាយ (ខេមបូឌា)។ របាយការណ៍គណនីអេឡិចត្រូនិក គឺប្រើប្រាស់សម្រាប់គោលបំណងជាព័ត៌មានតែប៉ុណ្ណោះ។
វិញ្ញាបនបត្របញ្ជាក់ពីបញ្ជើមានកាលកំណត់	ជាឯកសារព័ត៌មានអេឡិចត្រូនិចមួយនៃគណនីបញ្ជើមានកាលកំណត់របស់លោកអ្នកដែលបានបើកតាមរយៈធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ឬនៅតាមសាខារបស់ធនាគារ។
ប្រតិបត្តិការទូរស័ព្ទ	គឺជាប្រតិបត្តិការបណ្តាញទូរស័ព្ទចល័តដែលបានចូលរួមប្រតិបត្តិការ។
ការជូនដំណឹង	សំដៅដល់ និងរួមបញ្ចូលលើការផ្ញើសារ និងការជូនដំណឹងក្នុងកម្មវិធីទូរស័ព្ទដែលផ្ញើចូលទៅលោកអ្នកក្នុងពេលវេលាណាមួយពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារ ឬការជូនដំណឹងជាទូទៅដែលផ្ញើដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ។
ការទូទាត់	គឺជាការបញ្ជាទូទាត់ ដែលធ្វើឡើងតាមរយៈធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដើម្បីដកយកសាច់ប្រាក់ចេញពីគណនីរបស់លោកអ្នកសម្រាប់ការទូទាត់ណាមួយ; ឧទាហរណ៍៖ ទូទាត់សាច់ប្រាក់ដល់អ្នកលក់។
ព័ត៌មានផ្ទាល់ខ្លួន	សំដៅដល់ព័ត៌មានផ្ទាល់ខ្លួន ដែលត្រូវបានផ្តល់ដោយលោកអ្នកឲ្យទៅធនាគារ អេស ប៊ី អាយ (ខេមបូឌា) រួមមានប៉ុន្តែមិនកម្រិតដូចជា ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណ ថ្ងៃខែឆ្នាំកំណើត លេខទូរស័ព្ទទំនាក់ទំនង អ៊ីម៉ែល និងអាសយដ្ឋាន។
លេខកូដសម្ងាត់ (PIN)	គឺជាលេខលំដាប់ចំនួន ៦ ខ្ទង់ ដែលប្រើប្រាស់សម្រាប់ចូលប្រើប្រាស់ធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ហើយរួមបញ្ចូលទាំងលេខកូដសម្ងាត់ដំបូងដែលផ្តល់ដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដល់អតិថិជន ដើម្បីអាចចូលប្រើប្រាស់សេវាកម្មរបស់ធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) បាន។
កាតផ្លាស្ទិក	គឺជាប័ណ្ណឥណពន្ធ/ប័ណ្ណឥណទាន VISA ដែលចេញដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា)។
QR ស្កេន	គឺជាសេវាកម្មស្កេន QR កូដនៅក្នុងធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលអនុញ្ញាតឲ្យអតិថិជនធ្វើការស្កេន និងទូទាត់សាច់ប្រាក់នៅតាមហាងពាណិជ្ជកម្មជាដៃគូរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ឬស្កេនកូដ QR ជាទម្រង់ KHQR ដើម្បីដំណើរការប្រតិបត្តិការទៅតាមប្រភេទផ្សេងៗទៀត។
សារ OTP	One Time Password (OTP) គឺជាលេខកូដសម្ងាត់ ៦ ខ្ទង់ ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ហើយផ្ញើទៅកាន់ទូរស័ព្ទដៃរបស់ម្ចាស់គណនីតាមរយៈសារ (SMS) ដែលត្រូវប្រើជាចាំបាច់ដើម្បីគ្រប់គ្រងប្រតិបត្តិការទូទាត់សាច់ប្រាក់តាមប្រព័ន្ធអនឡាញ។
ប្រតិបត្តិការ	សំដៅដល់កំណត់ត្រាហិរញ្ញវត្ថុ ឬប្រតិបត្តិការ ដែលបានធ្វើឡើង ឬដាក់អនុវត្តដំណើរការ ឬត្រូវបានប្រតិបត្តិដោយលោកអ្នក ឬបុគ្គលណាម្នាក់ដែលអះអាងថាជាលោកអ្នក ឬបុគ្គលណាម្នាក់ដែលធ្វើសកម្មភាពជំនួសលោកអ្នក ដោយមាន ឬគ្មានការយល់ព្រមពីលោកអ្នក រួមបញ្ចូលទាំងការបង់ប្រាក់ ឬការផ្ទេរប្រាក់ទៅកាន់/ពី គណនីរបស់លោកអ្នក; រាល់ប្រតិបត្តិការធនាគារផ្សេងទៀតដែលបានធ្វើឡើងតាមរយៈធនាគារ អេស ប៊ី អាយ (ខេមបូឌា) ពីពេលមួយទៅពេលមួយទៀត (រួមបញ្ចូលទាំងការទូទាត់តាមវិក្កយបត្រ) និងប្រតិបត្តិការធនាគារណាមួយដែលធ្វើឡើងនៅតាមបណ្តាសាខារបស់ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ណាមួយ។
ប្រវត្តិប្រតិបត្តិការ	គឺជាការបង្ហាញអំពីបញ្ជីនៃការប្រតិបត្តិការទាំងឡាយណាដែលបានចូល ឬប្រើប្រាស់ដែលធ្វើឡើងជាមួយគណនីធនាគារ អេស ប៊ី អាយ (ខេមបូឌា) ក្នុងរយៈពេលជាក់លាក់ណាមួយ។
លេខសម្គាល់អ្នកប្រើប្រាស់	ជាលេខអត្តសញ្ញាណមួយ ដែលត្រូវបានផ្តល់ជូនទៅកាន់អ្នកប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) នៅពេលដែលមានការចុះឈ្មោះ។ ការកំណត់អត្តសញ្ញាណនេះ ប្រើសម្រាប់ការចូលទៅកាន់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)។ វាត្រូវបាន

	ទាមទារឲ្យធ្វើការដំឡើងនៅពេលបើកដំណើរការជាលើកដំបូង និងចងចាំសម្រាប់ការចូលប្រើប្រាស់នៅពេលក្រោយទៀត។
Jailbreak or Root	សំដៅលើទូរស័ព្ទដៃ ឬឧបករណ៍ចល័តផ្សេងទៀតដែលត្រូវបានផ្លាស់ប្តូរដើម្បីលុបការកំណត់ដែលកំណត់ដោយអ្នកក្រុមហ៊ុនផលិត ឬប្រតិបត្តិករ ដោយអនុញ្ញាតឱ្យដំឡើងកម្មវិធីដែលគ្មានអាជ្ញាប័ណ្ណ។
អ្នក, របស់អ្នក, និង របស់លោកអ្នក	សំដៅលើអតិថិជនដែលបានទាញយកនិងកំពុងប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)
យើង, យើងខ្ញុំ, និង របស់យើងខ្ញុំ	សំដៅលើ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ម.ក

១. សេចក្តីណែនាំ

លក្ខខណ្ឌទូទៅទាំងនេះ គ្រប់គ្រងលើការប្រើប្រាស់កម្មវិធីសេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលមានឈ្មោះថា "SBI Bank (Cambodia)"។ វាពិតជាមានការចាំបាច់ណាស់សម្រាប់អ្នកប្រើប្រាស់ធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ក្នុងការអាននូវលក្ខខណ្ឌទូទៅនេះដោយយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន។ តាមរយៈការចុះឈ្មោះ និងចូលប្រើប្រាស់ នោះមានន័យថាលោកអ្នកយល់ព្រមអនុលោមតាមលក្ខខណ្ឌទូទៅទាំងនេះហើយ។

តាមរយៈការចុចលើពាក្យថា "យល់ព្រម" បញ្ជាក់ថា លោកអ្នកបានអាន យល់ ទទួលស្គាល់ ទទួលយក និងបានបញ្ជាក់ពីការផ្តល់នូវការយល់ព្រមចំពោះលក្ខខណ្ឌទូទៅទាំងនេះ។

សូមធ្វើការកត់សម្គាល់ពិសេសផងដែរថា ធនាគារមានសិទ្ធិកែប្រែលក្ខខណ្ឌណាមួយដោយឯកត្តោភាគី និងពុំមានការជូនដំណឹងជាមុនឡើយ។ លក្ខខណ្ឌទាំងឡាយណាស្ថិតជាទម្រង់លាយលក្ខណ៍អក្សរផ្សេងទៀត ដែលទាក់ទងនឹងគណនី អេស ប៊ី អាយ (ខេមបូឌា) និងសេវាកម្មរបស់លោកអ្នកនឹងនៅតែបន្តអនុវត្ត។

ការប្រើប្រាស់នូវសេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ជាលើកដំបូង ដែលត្រូវបានធ្វើឡើងដោយម្ចាស់គណនី បន្ទាប់ពីម្ចាស់គណនីទទួលដឹងអំពីលក្ខខណ្ឌទូទៅនេះ គឺបង្ហាញពីការទទួលយកនូវលក្ខខណ្ឌទូទៅទាំងនេះហើយចាត់ទុកថាមានប្រសិទ្ធភាពអនុវត្តចាប់ពីពេលនោះតទៅ។

២. លក្ខខណ្ឌសម្រាប់អ្នកប្រើប្រាស់

- លោកអ្នក គឺជាម្ចាស់គណនី ធនាគារ អេស ប៊ី អាយ (ខេមបូឌា) តែម្នាក់គត់
- លោកអ្នក មានឧបករណ៍ប្រើប្រាស់/ទូរស័ព្ទដៃ ដែលអាចចូលប្រើប្រាស់ បាន (ដែលមិនមែនជាការធ្វើ rooted ឬ jailbreak)
- មានទូរស័ព្ទដៃដែលប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ iOS ឬ Android OS ឬ Hamony OS និងប្រើលេខទូរស័ព្ទទំនាក់ទំនង ដែលបានចុះឈ្មោះជាមួយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលនៅមានសុពលភាពនៅឡើយ
- លោកអ្នក ត្រូវតែជាបុគ្គលស្របច្បាប់ ឬមានអាយុចាប់ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ
- យល់ព្រមនឹងលក្ខខណ្ឌទូទៅនៃកម្មវិធីធនាគារចល័តរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ។

៣. ការបង្កើតគណនីកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)

ដើម្បីបង្កើតគណនីប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) លោកអ្នកតម្រូវអោយបង្កើតគណនីធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដោយផ្តល់នូវព័ត៌មាននិងឯកសារមួយចំនួនរួមមាន ឈ្មោះ ភេទ ទីកន្លែងកំណើត សញ្ជាតិ អាសយដ្ឋាន លេខទូរស័ព្ទ និង ព័ត៌មានឬឯកសារដែលចាំបាច់ផ្សេងៗទៀត។ លោកអ្នកធានាអះអាងថារាល់ព័ត៌មានដែលអ្នកបានផ្តល់អោយគឺព័ត៌មានពិត និងត្រឹមត្រូវគ្រប់ទិដ្ឋភាពទាំងអស់សម្រាប់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ក្នុងការធ្វើដំណើរការនិងគ្រប់គ្រងការប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) របស់លោកអ្នក។ ការខកខានក្នុងការផ្តល់ព័ត៌មាន ឯកសារពិត និងត្រឹមត្រូវ គឺជាការទទួលខុសត្រូវរបស់អ្នក តែម្នាក់គត់។ប្រសិនបើព័ត៌មានរបស់អ្នកដែលផ្តល់ឱ្យ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ផុតមានសុពលភាព អ្នកអាចស្នើសុំទៅ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដើម្បីកែប្រែព័ត៌មានទាំងនោះគ្រប់ពេលវេលាតាមរយៈផ្នែកបម្រើសេវាកម្មអតិថិជនដែលមាន។

សម្រាប់ការបង្កើតគណនីដំបូង លោកអ្នកនឹងទទួលបាននូវគណនីចំនួន២គណនី ដែលជារូបិយប័ណ្ណពីរផ្សេងគ្នា ដោយគណនីទី១ គឺជាគណនីរូបិយប័ណ្ណខ្មែររៀល និងគណនីទី២ គឺជាគណនីរូបិយប័ណ្ណដុល្លារសហរដ្ឋអាមេរិក។

៤. គោលការណ៍ឯកជនភាព

សម្រាប់ការប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) លោកអ្នកយល់ព្រមជាមួយគោលការណ៍ឯកជនភាពរបស់យើងដែលបានដាក់បញ្ចូលទៅក្នុងលក្ខខណ្ឌទាំងនេះ ឬអាចមើលបានតាមរយៈគេហទំព័រផ្លូវការរបស់យើង។ គោលការណ៍ឯកជនភាពអាចត្រូវបានកែប្រែពីពេលមួយទៅពេលមួយ តាមការសម្រេចចិត្តតែរបស់យើងតែមួយគត់។

៥. សកម្មភាពហាមឃាត់

៣.១ អ្នកមិនអាចចូល ឬប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) សម្រាប់គោលបំណងផ្សេងណាមួយក្រៅពីយើងដាក់ដំណើរការក្នុងកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) នោះទេ។ កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) មិនត្រូវបានប្រើប្រាស់ពាក់ព័ន្ធនឹងការផ្សព្វផ្សាយណាមួយឡើយ លើកលែងតែអ្វីដែលត្រូវបានគាំទ្រជាពិសេសឬអនុម័តដោយយើង។

៣.២ ក្នុងនាមជាអ្នកប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អ្នកយល់ព្រមនឹងមិនធ្វើសកម្មភាពដូចខាងក្រោម:

ក. ទាញយកទិន្នន័យ ឬខ្លឹមសារផ្សេងៗពីកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដើម្បីបង្កើត ឬចងក្រងដោយផ្ទាល់ ឬដោយប្រយោល ដែលជាការប្រមូល ការចងក្រង មូលដ្ឋានទិន្នន័យ ឬថតឯកសារដោយគ្មានការអនុញ្ញាតពីយើងខ្ញុំ។

ខ. ប្រើប្រាស់កម្មវិធីធនាគារចល័តអេស ប៊ី អាយ (ខេមបូឌា) ដើម្បីផ្សព្វផ្សាយ ឬលក់ទំនិញ និងសេវាកម្មផ្សេងៗ។

គ. បោកបញ្ឆោត បោកប្រាស់ ឬបំភាន់ធនាគារ (យើង) និងអ្នកប្រើប្រាស់ផ្សេងទៀតក្នុងគោលបំណងស្វែងរកព័ត៌មានសម្ងាត់គណនីដូចជា លេខកូដសម្ងាត់ជាដើម។

ឃ. ព្យាយាមក្លែងបន្លំជាអ្នកប្រើប្រាស់ ឬបុគ្គលផ្សេងទៀត ឬប្រើឈ្មោះរបស់អ្នកប្រើប្រាស់ផ្សេងទៀត។

ង. ប្រើប្រាស់ព័ត៌មានដែលទទួលបានពីកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដើម្បី បៀតបៀន រំលោភបំពាន ឬបង្ករគ្រោះថ្នាក់ផ្សេងៗដល់បុគ្គលផ្សេងទៀត។

ច. បៀតបៀន រំខាន បំភិតបំភ័យ ឬគំរាមកំហែងដល់បុគ្គលិក ឬភ្នាក់ងាររបស់យើងដែលចូលរួមក្នុងការគាំទ្រផ្នែកណាមួយនៃកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដល់អ្នក។

៦. ការពិពណ៌នាអំពីសេវាកម្ម

លោកអ្នកអាចចូលទៅប្រើប្រាស់សេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដោយប្រើប្រាស់នូវលេខសម្គាល់អ្នកប្រើប្រាស់ លេខកូដសម្ងាត់ ទិន្នន័យមុខ ឬស្នាមម្រាមដៃ ដែលត្រូវបានផ្តល់ឲ្យលោកអ្នកដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា) នៅពេលដែលលោកអ្នកធ្វើការចុះឈ្មោះប្រើប្រាស់។

សូមចូលទៅកាន់គេហទំព័រធនាគារ អេស ប៊ី អាយ (ខេមបូឌា) សម្រាប់សេវាកម្មផ្សេងៗរបស់របស់ធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)។

សម្រាប់ព័ត៌មានលម្អិតអំពីមុខងារ និងសេវាកម្មរបស់ធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) សូមមើលឧបសម្ព័ន្ធទី២។

៧. ព័ត៌មានអំពីគណនី

គណនីទាំងអស់របស់លោកអ្នក ដែលប្រើប្រាស់សម្រាប់សេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ក្រោមអត្តសញ្ញាណរបស់លោកអ្នក វានឹងបង្ហាញនៅក្នុងកម្មវិធីចល័តរបស់លោកអ្នក ហើយលោកអ្នកនឹងអាចបន្ថែមគណនីដើម្បីដាក់បង្ហាញខាងមុខ និងកំណត់គណនីរបស់លោកអ្នកសម្រាប់ការធ្វើប្រតិបត្តិការ ឬត្រឹមតែការសាកសួរព័ត៌មាន។

សមតុល្យទាំងឡាយណាសម្រាប់គណនីត្រូវបានជ្រើសរើសក្នុងការភ្ជាប់ ដែលលោកអ្នកទទួលបានតាមរយៈកម្មវិធីធនាគារចល័ត អេស ប៊ី អាយ (ខេមបូឌា) នឹងក្លាយជាសមតុល្យក្នុងពេលបច្ចុប្បន្ន (មិនរាប់បញ្ចូលការប្រើប្រាស់ចំនួនសមតុល្យជាអប្បបរមា) ដូចដែលក្នុងពេលលោកអ្នកធ្វើការសាកសួរ ហើយនឹងអាចមិនរាប់បញ្ចូលនូវទឹកប្រាក់ដែលត្រូវបានជម្រះរួច (ឧទាហរណ៍៖ មូលប្បទានប័ត្រដែលមិនទាន់ត្រូវបានជម្រះ)។

អ្នកក៏អាចធ្វើការស្វែងរក និងមើលប្រតិបត្តិការទាំងអស់ ដែលធ្វើឡើងនៅលើគណនីរបស់លោកអ្នកដែលត្រូវបានជ្រើសរើសក្នុងការភ្ជាប់រហូតដល់មួយខែចុងក្រោយនៅលើសេវាកម្មធនាគារចល័ត អេស ប៊ី អាយ (ខេមបូឌា) ។

រាល់គណនីទាំងឡាយណា ដែលត្រូវបានបើក និងគ្រប់គ្រងជាមួយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ក្នុងព្រះរាជាណាចក្រកម្ពុជា គឺអាចភ្ជាប់ជាមួយនឹងសេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ក្នុងករណីដែលផ្ទុយពីការចែងនេះនឹងមិនអាចភ្ជាប់បានឡើយ។

ក្នុងករណីដែលត្រូវបានហាមឃាត់ដោយច្បាប់ ឬក្នុងករណីដែលធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដាក់កម្រិត ឬមិនអនុម័ត គណនីដែលលោកអ្នកបានជ្រើសរើសក្នុងការភ្ជាប់ជាមួយកម្មវិធីធនាគារចល័ត ស្របតាមការសម្រេចជាឯកត្តោភាគី នោះធនាគារ អេស ប៊ី អាយ (ខេមបូឌា) នឹងជូនដំណឹងដល់លោកអ្នកអំពីការដាក់កម្រិត ឬការមិនអនុម័តនេះ។

ម្ចាស់គណនី:

- អតិថិជនជាបុគ្គល: ម្ចាស់គណនីគោល នឹងអាចពិនិត្យមើលបានតែគណនី ដែលស្ថិតនៅក្រោមលេខ CIF ដូចគ្នាតែប៉ុណ្ណោះ។
- ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចដាក់កម្រិតលើការប្រើប្រាស់សេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) របស់លោកអ្នកលើគណនីដែលបានជ្រើសរើសក្នុងការភ្ជាប់។ ឧទាហរណ៍៖

ធនាគារ អេស ប៊ី អាយ (ខេមបូឌា) កំណត់ចំនួននៃប្រតិបត្តិការគ្រប់ប្រភេទចំពោះគណនីដែលបានជ្រើសរើសក្នុងការភ្ជាប់។

ប្រតិបត្តិការដែលមិនត្រូវបានអនុញ្ញាត:

ប្រការនេះកំណត់ពីការទទួលខុសត្រូវរបស់ភាគីលើប្រតិបត្តិការ ដែលមិនមានការអនុញ្ញាតធ្វើឡើងតាមរយៈការប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)។

ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ទទួលខុសត្រូវក្នុងករណីដែលៈ

- ធនាគារ អេស ប៊ី អាយ (ខេមបូឌា) នឹងទទួលខុសត្រូវលើរាល់ការបាត់បង់ជាក់ស្តែង ដែលបានកើតឡើងចំពោះម្ចាស់គណនីដែលបណ្តាលមកពី ការក្លែងបន្លំ ឬការធ្វេសប្រហែសរបស់បុគ្គលិកធនាគារ អេស ប៊ី អាយ (ខេមបូឌា)។

ម្ចាស់គណនី ទទួលខុសត្រូវក្នុងករណីដែលៈ

- ទោះបីជាធនាគារយើងខ្ញុំខិតខំប្រឹងប្រែងអស់ពីលទ្ធភាព ក្នុងការផ្តល់សេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ក៏ដោយ យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះការខកខានក្នុងការផ្តល់សេវាកម្មទាំងនោះឡើយ មិនថាដោយផ្នែក ឬទាំងស្រុងនោះទេ ដោយយោងតាមកាលៈទេសៈមិនប្រក្រតី និងស្ថានការណ៍ដែលមិនអាចប៉ាន់ប្រមាណទុកជាមុន ឬលើសពីការគ្រប់គ្រងរបស់យើងខ្ញុំ ដែលអាចកើតមាន។ ការមិនទទួលខុសត្រូវក៏រួមបញ្ចូលផងដែរទាំងលើ បញ្ហាបណ្តាញប្រព័ន្ធទូរស័ព្ទ និងបញ្ហាមិនដំណើរការប្រព័ន្ធអ៊ីនធើណេត ជាដើម។
- កម្មវិធីធនាគារចល័តត្រូវបានផ្តល់ជូន "ទៅតាមចរិតលក្ខណៈនៃសេវាកម្ម" ដែលមិនត្រូវចាត់ទុកជាការតំណាង ការធានា ឬកិច្ចព្រមព្រៀងនៃមុខងារនីមួយៗឡើយ។ យើងខ្ញុំមិនអាចធានាបានទេថា មិនមានមេរោគ មិនមានការថតចម្លង/ទាញយកទិន្នន័យពីឧបករណ៍ប្រើប្រាស់របស់លោកអ្នក មិនមានការចម្លងមេរោគផ្សេងទៀត ឬការបំផ្លិចបំផ្លាញរបស់ជាកម្មសិទ្ធិដែលនឹងត្រូវបញ្ជូន ឬដែលមិនមានការខូចខាតណាមួយកើតឡើងចំពោះទូរស័ព្ទដៃ ឬឧបករណ៍ប្រើប្រាស់ណាមួយរបស់លោកអ្នក។ យើងខ្ញុំមិនទទួលខុសត្រូវនូវរាល់ការបាត់បង់ណាមួយដែលអាចកើតមានឡើងដូចករណីខាងលើនេះឡើយ។
- បន្ថែមពីលើទំនួលខុសត្រូវដែលបានចែងក្នុងលក្ខខណ្ឌទូទៅនៃគណនីរបស់លោកអ្នក ម្ចាស់គណនីត្រូវទទួលខុសត្រូវនូវរាល់ការបាត់បង់ទឹកប្រាក់ ឬការទាញយកព័ត៌មានណាមួយតាមរយៈការចូលប្រើប្រាស់គណនីណាមួយដោយគ្មានការអនុញ្ញាតពីម្ចាស់គណនី ប្រសិនបើម្ចាស់គណនីចូលរួមចំណែកក្នុងការប្រើប្រាស់ដោយគ្មានការអនុញ្ញាតៈ
  - តាមរយៈការក្លែងបន្លំ ឬការធ្វេសប្រហែសរបស់លោកអ្នក
  - ដោយការស្ម័គ្រចិត្តបង្ហាញលេខកូដសម្ងាត់ ឬលេខកូដផ្ទៀងផ្ទាត់របស់លោកអ្នកទៅកាន់នរណាម្នាក់ ដែលក្នុងនោះរួមមាន សមាជិកគ្រួសារ ឬមិត្តភក្តិ ជាដើម
  - ដោយការរក្សាទុកកំណត់ត្រាលេខកូដសម្ងាត់ ឬលេខកូដផ្ទៀងផ្ទាត់ (ដែលមិនមានការបិទបាំងឬការពារមិនឲ្យអ្នកដទៃស្គាល់)
    - ស្ថិតលើឧបករណ៍សុវត្ថិភាព ឬជាមួយលេខកូដសម្គាល់អ្នកប្រើប្រាស់
    - ស្ថិតលើអត្ថបទទាំងឡាយណាដែលភ្ជាប់ជាមួយឧបករណ៍សុវត្ថិភាព ឬជាមួយលេខកូដសម្គាល់អ្នកប្រើប្រាស់

- ស្ថិតក្នុង ឬលើអ្វីមួយដែលអាចបាត់ ឬត្រូវបានលួចក្នុងពេលតែមួយទាំងឧបករណ៍សុវត្ថិភាព ឬលេខកូដសម្គាល់អ្នកប្រើប្រាស់។

➢ ដោយការប្រើប្រាស់លេខកូដសម្ងាត់ ដែលងាយស្រួលនឹងកំណត់អត្តសញ្ញាណរបស់លោកអ្នកដូចជា ថ្ងៃខែកំណើត កាលបរិច្ឆេទចុះឈ្មោះ លេខទូរស័ព្ទ ឬឈ្មោះរបស់លោកអ្នក

➢ ដោយប្រើប្រាស់លេខកូដសម្ងាត់តែមួយក្នុងគោលបំណងជាច្រើន រួមទាំងលើសេវាកម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)

➢ ដើម្បីរក្សាការគ្រប់គ្រងលើគណនី និងការពារការចូលប្រើប្រាស់គណនីពីជនណាម្នាក់ ម្ចាស់គណនីគួរតែរក្សាការគ្រប់គ្រងលើការចូលប្រើប្រាស់លើឧបករណ៍ប្រើប្រាស់ក្នុងការចូលទៅកាន់កម្មវិធីធនាគារចល័តរបស់លោកអ្នក។ លោកអ្នកទទួលខុសត្រូវចំពោះការធ្វើបច្ចុប្បន្នភាព និងរក្សាភាពសុក្រឹតនៃព័ត៌មានដែលលោកអ្នកបានផ្តល់ឲ្យដើម្បីប្រើប្រាស់ពាក់ព័ន្ធជាមួយនឹងគណនីរបស់លោកអ្នក។

- ប្រសិនបើព័ត៌មានគណនីរបស់លោកអ្នក ត្រូវបានលួច និងគ្រប់គ្រងដោយជនខិលខូចដើម្បីធ្វើប្រតិបត្តិការណាមួយ លោកអ្នកត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ផ្នែកហិរញ្ញវត្ថុណាមួយចេញពីសកម្មភាពនេះ។
- ប្រសិនបើក្រោយពេលដែលលោកអ្នកបានដឹងអំពីការខូចខាត ការលួច ឬការរំលោភបំពានលើសុវត្ថិភាពនៃលេខកូដសម្ងាត់របស់លោកអ្នកហើយ លោកអ្នកមិនជូនដំណឹងភ្លាមៗមកកាន់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ទេ លោកអ្នកត្រូវទទួលខុសត្រូវចំពោះការខូចខាតជាក់ស្តែងដែលកើតមានឡើងរវាង៖

➢ កាលណាដែលលោកអ្នក បានដឹងតាំងពីដំបូងអំពីព្រឹត្តិការណ៍ណាមួយដែលបានពិពណ៌នាខាងលើ ឬករណីខូចខាត ឬការលួចនូវឧបករណ៍សុវត្ថិភាព លោកអ្នកគួរតែដឹងអំពីការខូចខាត ការលួច និងពេលដែលធនាគារ អេស ប៊ី អាយ (ខេមបូឌា) បានជូនដំណឹងអំពីបញ្ហាពាក់ព័ន្ធ

➢ មិនបានចូលទៅប្តូរលេខកូដសម្ងាត់បន្ទាប់ពីបានចុះឈ្មោះប្រើប្រាស់ហើយ។

៨. ការម្រិតនៃសេវាកម្ម

ការកម្រិតប្រតិបត្តិការ៖ ផ្អែកតាមការយល់ព្រមលើលក្ខខណ្ឌទូទៅនេះ មានន័យថាលោកអ្នកយល់ព្រមក្នុងការកម្រិតប្រតិបត្តិការដែលត្រូវបានកំណត់ដោយ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) និងច្បាប់ជាធរមាន។ លោកអ្នក អាចធ្វើការស្វែងរកសាខារបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលនៅជិតលោកអ្នកបំផុតដើម្បីជ្រាបអំពីព័ត៌មានលម្អិតលើការកម្រិតសេវាកម្ម ឬទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ (៨៥៥) ០២៣ ៩៨០ ៨៨៨ ឬ ០៩៣ ៦៧១ ១១១។ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) រក្សាសិទ្ធិក្នុងការកែប្រែទំហំនៃការកម្រិតប្រតិបត្តិការជាប្រចាំថ្ងៃដោយពុំចាំបាច់មានការជូនដំណឹងជាមុនឡើយ។

សម្រាប់ព័ត៌មានលម្អិតអំពីការកម្រិតផ្អែកប្រតិបត្តិការ សូមមើលឧបសម្ព័ន្ធ"ក"។

ការកម្រិតការចូលប្រើប្រាស់៖ លោកអ្នកមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់នូវកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ឡើយប្រសិនបើប្រព័ន្ធប្រតិបត្តិការលើឧបករណ៍ប្រើប្រាស់របស់លោកអ្នក គឺមានភាពមិនប្រក្រតី (ដោយត្រូវបាន rooted ឬ jailbreak)។

ការថែទាំប្រព័ន្ធ៖ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចបន្ថែម ឬផ្អាកដំណើរការមុខងារណាមួយ ឬព្យួរនូវប្រតិបត្តិការធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ឬសេវាកម្មរបស់ខ្លួនមួយណាក៏បានសម្រាប់គោលបំណងនៃការអនុវត្តការថែទាំប្រព័ន្ធជាប្រចាំ និងការងាររដ្ឋបាល។ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) នឹងស្នើឲ្យអ្នក

ប្រើប្រាស់ទាំងអស់ធ្វើបច្ចុប្បន្នភាពកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ទៅជំនាន់ចុងក្រោយបង្អស់ដើម្បីសុវត្ថិភាព និងហេតុផលដំណើរការត្រូវគ្នា។ លោកអ្នកមិនអាចបន្តប្រើប្រាស់កម្មវិធីនៅជំនាន់ចាស់បាននោះទេ លុះត្រាតែអ្នកធ្វើបច្ចុប្បន្នភាពទៅជំនាន់ចុងក្រោយបង្អស់។

៩. កម្រៃសេវាកម្ម និងការចំណាយផ្សេងៗ

កាលណាលោកអ្នកប្រើប្រាស់ធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដើម្បីធ្វើប្រតិបត្តិការធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចដាក់ឲ្យប្រើប្រាស់នូវកម្រៃសេវាកម្ម និងការចំណាយផ្សេងៗ។ លោកអ្នកយល់ព្រមបង់ និងផ្តល់សិទ្ធិឲ្យធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដកសាច់ប្រាក់ដោយផ្ទាល់ចេញពីគណនីរបស់លោកអ្នក។ កម្រៃសេវាកម្ម និងការចំណាយផ្សេងៗទាំងនោះអាចនឹងត្រូវបានកែប្រែដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ពីអំឡុងពេលមួយទៅអំឡុងពេលមួយ។ សម្រាប់ព័ត៌មានលម្អិតអំពីកម្រៃសេវាកម្ម និងការចំណាយថ្មីៗ នឹងអាចផ្តល់ជូនបាននៅតាមបណ្តាសាខារបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលនៅជិតលោកអ្នកបំផុត ឬចូលទៅកាន់គេហទំព័ររបស់យើងខ្ញុំ។

លោកអ្នកអាចនឹងត្រូវទូទាត់ការចំណាយផ្សេងៗពីក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទចល័ត សម្រាប់ការទាញយក ការធ្វើបច្ចុប្បន្នភាព និងការប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)។ រាល់ការចំណាយទាំងអស់ គឺជាការទទួលខុសត្រូវរបស់លោកអ្នកតែម្នាក់ប៉ុណ្ណោះ និងរាល់បញ្ហានានាដែលពាក់ព័ន្ធនឹងការចំណាយនេះគួរតែចោទជាសំណួរទៅកាន់ប្រតិបត្តិកររបស់លោកអ្នក។ លោកអ្នកគួរគប្បីទំនាក់ទំនងទៅកាន់ប្រតិបត្តិករសម្រាប់ព័ត៌មានលម្អិតអំពីកម្រៃសេវាកម្ម និងការចំណាយផ្សេងៗលើការប្រើប្រាស់សេវាកម្មធនាគារចល័ត។

១០. រូបិយប័ណ្ណ

រាល់ប្រតិបត្តិការចេញ និងចូលក្នុងគណនីរបស់លោកអ្នក តាមរយៈកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ជារូបិយប័ណ្ណផ្សេងក្រៅអំពីរូបិយប័ណ្ណដែលគណនីរបស់លោកអ្នកត្រូវបានជ្រើសរើស នឹងត្រូវទូទាត់ដោយអត្រាប្តូរប្រាក់ដែលត្រូវអនុវត្តចំពោះរូបិយប័ណ្ណនៃប្រតិបត្តិការដែលពាក់ព័ន្ធនៅអំឡុងពេលប្រតិបត្តិការដែលអត្រានេះត្រូវកំណត់ដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា)។ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) នឹងកំណត់អត្រាប្តូរប្រាក់ដើម្បីប្តូរបរិមាណរូបិយប័ណ្ណបរទេសទៅជាបរិមាណសមមូលជារូបិយប័ណ្ណផ្សេងៗ ឬរូបិយប័ណ្ណក្នុងស្រុក នៃព្រះរាជាណាចក្រកម្ពុជា ហើយលោកអ្នកយល់ព្រម និងទទួលស្គាល់អត្រាប្តូរប្រាក់ដែលបានប្តូរនោះ។

១១. សុវត្ថិភាពលេខកូដសម្ងាត់

កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ព្រមទាំងរាល់សេវាកម្មរបស់ធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) តម្រូវអោយប្រើប្រាស់អត្តសញ្ញាណប័ណ្ណសុវត្ថិភាពដែលមាន លេខសម្គាល់អ្នកប្រើប្រាស់ និង លេខកូដសម្ងាត់៦ខ្ទង់។

- ករណីបើការផ្ទៀងផ្ទាត់អត្តសញ្ញាណត្រូវបានដឹងដល់នរណាម្នាក់ក្រៅពីអតិថិជន/អ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាត បុគ្គលនោះអាចត្រូវបានធគានារចាត់ទុកថាជាអ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាត ហើយធនាគារនឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតដែលអាចកើតឡើងដោយសារតែការផ្ទៀងផ្ទាត់អត្តសញ្ញាណដែលត្រូវបានស្គាល់ដល់អ្នកដទៃនោះទេ។ ប្រសិនបើ អតិថិជន/អ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាតបានដឹងឬសង្ស័យថាមានបុគ្គលណាម្នាក់ផ្សេងបានដឹងពីការផ្ទៀងផ្ទាត់អត្តសញ្ញាណ អតិថិជន/អ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាត ត្រូវជូនដំណឹងទៅធនាគារភ្លាមៗ។

- មិនត្រូវប្រើប្រាស់លេខណាដែលត្រូវបានស្គាល់ជាសាធារណៈ និងលេខដែលងាយក្នុងការទាយពី ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដូចជា ថ្ងៃខែកំណើត លេខទូរស័ព្ទ និងលេខបន្តបន្ទាប់។
- មិនត្រូវទុកឧបករណ៍ចល័តដោយមិនធ្វេសប្រហែស ខណៈពេលដែលលោកអ្នកចូលប្រើប្រាស់គណនីរបស់ខ្លួន និងកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)
- ត្រូវប្រាកដថាព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងប្រព័ន្ធសុវត្ថិភាពរបស់លោកអ្នកក្នុងការចូលប្រើប្រាស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) នៅតែក្សាការសម្ងាត់ចំពោះលោកអ្នកតែម្នាក់ និងចាត់វិធានការសមស្របណាមួយដើម្បីការពារនូវរាល់ព័ត៌មានទាំងនោះពីការលាតត្រដាង។ ឧទាហរណ៍៖ អ្នកត្រូវតែចងចាំនូវរាល់ព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងប្រព័ន្ធសុវត្ថិភាពរបស់លោកអ្នក កុំសរសេរឬរក្សាទុកព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងប្រព័ន្ធសុវត្ថិភាពរបស់លោកអ្នកនៅគ្រប់ទីកន្លែងទោះស្ថិតក្នុងទម្រង់ណាក៏ដោយ រួមទាំងប្រព័ន្ធអេឡិចត្រូនិក ឧទាហរណ៍ដូចជានៅក្នុងទូរស័ព្ទដៃ ឬឧបករណ៍ចល័តរបស់លោកអ្នក។
- ត្រូវប្រាកដថាមិនមានជនណាម្នាក់អាចកត់សម្គាល់ឃើញ នៅពេលដែលលោកអ្នកបញ្ចូលព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងប្រព័ន្ធសុវត្ថិភាពលើកម្មវិធីធនាគារចល័តរបស់លោកអ្នក។
- អ្នកគួរគប្បីតំឡើងកម្មវិធីណាដែលមានអាជ្ញាប័ណ្ណ ហើយអ្នកមិនត្រូវ jailbreak ឬ root ទូរស័ព្ទដៃរបស់អ្នកទេ។
- អ្នកគួរតែប្រើប្រាស់ស៊ីមកាតណាដែលបានចុះឈ្មោះត្រឹមត្រូវជាមួយបណ្តាញប្រតិបត្តិការទូរស័ព្ទណាមួយ មិនគួរប្រើប្រាស់ស៊ីមកាតណាដែលបានមិនចុះឈ្មោះត្រឹមត្រូវនៅលើទូរស័ព្ទដៃរបស់អ្នកទេ។

ការបញ្ចូលលេខកូដសម្ងាត់ខុស៣ដង ប្រព័ន្ធនឹងធ្វើការផ្អាកការប្រើប្រាស់កម្មវិធីធនាគារចល័តជាបណ្តោះអាសន្ន។ លោកអ្នកត្រូវតែទាក់ទងទៅកាន់ការិយាល័យសេវាកម្មអតិថិជនដើម្បីស្នើសុំប្រើប្រាស់ឡើងវិញ។

ធនាគារ អេស ប៊ី អាយ (ខេមបូឌា) លើកទឹកចិត្តអោយលោកអ្នកប្តូរលេខកូដសម្ងាត់ជាប្រចាំ។ ប្រសិនបើទូរស័ព្ទ/លេខទូរស័ព្ទ ត្រូវបានបាត់បង់ ឬត្រូវបានលួច ឬមានប្រតិបត្តិការមិនប្រក្រតីណាមួយបានកើតឡើងលើគណនីដែលលោកអ្នកបានតភ្ជាប់ជាមួយកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) លោកអ្នកត្រូវជូនដំណឹងមកកាន់ធនាគារភ្លាមៗ។

លោកអ្នកជាអ្នកប្រើឧបករណ៍ចល័ត លោកអ្នកអាចធ្វើការជ្រើសរើសបើកការផ្ទៀងផ្ទាត់ជីវមាត្រដើម្បីចូលទៅក្នុងកម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដោយប្រើការកំណត់អត្តសញ្ញាណជីវមាត្រដែលបានចុះឈ្មោះនៅលើឧបករណ៍ចល័តរបស់លោកអ្នក។ ចំណែកឯការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវសម្រាប់ប្រតិបត្តិការនៅតែប្រើលេខកូដសម្ងាត់៦ខ្ទង់ដែលត្រូវបានបង្កើតឡើងនៅពេលធ្វើឱ្យសកម្ម ឬផ្លាស់ប្តូរលេខកូដសម្ងាត់។

កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) មិនប្រមូល ឬរក្សាទុកការផ្ទៀងផ្ទាត់ជីវមាត្រនេះទេ ប៉ុន្តែវាត្រូវបានរក្សាទុកនៅលើឧបករណ៍ចល័តរបស់លោកអ្នក។

១២. ការកែប្រែនៃលក្ខខណ្ឌទូទៅ និងនៃកម្រៃសេវាកម្ម និងចំណាយផ្សេងៗ

ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចធ្វើការកែប្រែ ឬបន្ថែមទៅលើលក្ខខណ្ឌទូទៅទាំងនេះ និងកម្រៃសេវាកម្ម និងចំណាយផ្សេងៗដែលអនុវត្តចំពោះកម្មវិធីធនាគារចល័តរបស់ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) តាមការសម្រេចរបស់ធនាគារតែម្ខាង ឬតម្រូវតាមច្បាប់ជាធរមាន ឬបទប្បញ្ញត្តិផ្សេងៗ។

ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចធ្វើការផ្លាស់ប្តូរលើលក្ខខណ្ឌទូទៅទាំងនេះ និងកម្រៃសេវាកម្ម និងចំណាយផ្សេងៗដែលអនុវត្តចំពោះកម្មវិធីធនាគារចល័តរបស់ ធនាគារ អេស ប៊ី អាយ (ខេមបូឌា) នៅពេលណាមួយក៏បាន

ដោយមិនចាំបាច់មានការជូនដំណឹងជាមុនឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការចំណាយផ្សេងៗ ដែលអនុវត្តក្នុងចំណុចកម្រៃសេវាកម្ម និងចំណាយផ្សេងៗ គឺអាចរកឃើញបាននៅលើប័ណ្ណផ្សព្វផ្សាយក្នុងកម្មវិធីធនាគារចល័ត អេស ប៊ី អាយ (ខេមបូឌា) ម៉ាស៊ីន អេ ធី អឹម ឬគេហទំព័ររបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ។

១៣. ការការពារការសម្ងាត់ប្រាក់ និងបន្ថែមផ្សេងៗ

តាមរយៈការយល់ព្រមលើលក្ខខណ្ឌទូទៅទាំងនេះ លោកអ្នកទទួលស្គាល់ថា ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចធ្វើការពន្យាពេល ទប់ស្កាត់ ឬបដិសេធមិនឲ្យមានដំណើរការប្រតិបត្តិការណាមួយ ដោយមិនមានការទទួលខុសត្រូវឡើយ ក្នុងករណីដែលធនាគារ អេស ប៊ី អាយ (ខេមបូឌា) សង្ស័យថា៖

១. ប្រតិបត្តិការនោះ អាចរំលោភបំពានច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត

២. ប្រតិបត្តិការនេះ អាចមានជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលនូវប្រាក់ចំណូល ឬត្រូវបានអនុវត្តសម្រាប់គោលបំណងនៃការប្រព្រឹត្តអំពើខុសច្បាប់។

លោកអ្នកត្រូវតែផ្តល់ព័ត៌មានទាំងអស់ដល់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលអេស ប៊ី អាយ (ខេមបូឌា) មានការតម្រូវដោយសមហេតុផល ដើម្បីគ្រប់គ្រងការសម្អាតប្រាក់ ហានិភ័យហិរញ្ញប្បទានភេរវកម្ម និងសេដ្ឋកិច្ច និងហានិភ័យផ្នែកពាណិជ្ជកម្ម ឬដើម្បីអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត ឬដើម្បីអនុវត្តតាមការហាមឃាត់ផ្សេងទៀតដែលធនាគារ អេស ប៊ី អាយ (ខេមបូឌា) អនុវត្តទាក់ទងនឹងប្រតិបត្តិការណាមួយ ហើយលោកអ្នកយល់ព្រមថាធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចបង្ហាញព័ត៌មានណាមួយដែលទាក់ទងនឹងអ្នកចំពោះ៖

៣. រាល់ច្បាប់ចូលជាធរមាន ទីភ្នាក់ងាររបស់និយ័តករ ឬតុលាការ ដែលតម្រូវដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬតំបន់ផ្សេងទៀត

៤. រាល់ការទំនាក់ទំនងដែលធនាគារ អេស ប៊ី អាយ (ខេមបូឌា) ប្រើប្រាស់ដើម្បីធ្វើការទូទាត់សម្រាប់គោលបំណងដែលអនុលោមតាមច្បាប់។ ក្នុងករណីដែលលោកអ្នកមិនបានបង្ហាញឱ្យឃើញថាលោកអ្នកមានការទទួលខុសត្រូវទៅលើសកម្មភាពដែលលោកអ្នកបានធ្វើ ឬក្នុងនាមបុគ្គលផ្សេងទៀត លោកអ្នកត្រូវធានាថាលោកអ្នកមានការទទួលខុសត្រូវទៅលើសកម្មភាពផ្ទាល់ខ្លួនដែលលោកអ្នកបានធ្វើតាមរយៈការយល់ព្រមស្របតាមលក្ខខណ្ឌទូទៅទាំងនេះ។

លោកអ្នកប្រកាស យល់ព្រម និងអនុវត្តតាមធនាគារ អេស ប៊ី អាយ (ខេមបូឌា) ថាចំពោះការទូទាត់ប្រាក់ជាមួយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ស្របតាមការណែនាំរបស់លោកអ្នក គឺមិនមានការរំលោភបំពានច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬយុត្តាធិការណាមួយឡើយ។

១៤. ការបដិសេធមិនផ្តល់សេវាកម្ម

ទោះបីជាមានសិទ្ធិណាមួយដែលមានចែងនៅក្នុងលក្ខខណ្ឌទូទៅនេះក៏ដោយ ក៏ក្នុងករណីដែលលោកអ្នកទទួលបានការអនុញ្ញាតនោះ យើងខ្ញុំអាចធ្វើការបដិសេធបានភ្លាមៗស្ថិតក្នុងពេលដំណើរការ ឬពេលបញ្ចប់ប្រតិបត្តិការ ឬការផ្អាកការផ្តល់នូវផលិតផលណាមួយ ឬសេវាកម្មដល់លោកអ្នក បដិសេធមិនអនុញ្ញាត ឬសម្រួលដល់ទ្រព្យសកម្មរបស់លោកអ្នកដែលត្រូវបានគ្រប់គ្រងដោយយើងខ្ញុំ ដើម្បីប្រើប្រាស់ ឬដោះស្រាយជាមួយ បដិសេធមិនប្រគល់ទ្រព្យសកម្មណាមួយដល់លោកអ្នក ដែលអាចនឹងផ្តល់ជូនបុគ្គលផ្សេងទៀត ឬបញ្ចប់ការចាត់ចែងទាំងនេះជាមួយលោកអ្នក។ យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះលោកអ្នកទេ ប្រសិនបើយើងខ្ញុំអនុវត្តផ្នែកណាមួយ ឬទាំងស្រុងនៃ

សកម្មភាពទាំងនេះ។ ក្នុងករណីដែលយើងខ្ញុំអនុវត្តសិទ្ធិរបស់យើងខ្ញុំក្រោមប្រការខាងលើនេះ លោកអ្នកត្រូវបង់សំណងការខូចខាត សោហ៊ុយ ឬការចំណាយផ្សេងៗដែលកើតឡើងទាក់ទងនឹងសកម្មភាពណាមួយត្រូវបានធ្វើឡើងក្រោមប្រការទាំងលើនេះ រួមទាំងការទូទាត់សំណងការប្រាក់ និង/ឬការចំណាយរដ្ឋបាលផ្សេងៗក្រោមលក្ខខណ្ឌទូទៅទាំងនេះ។

១៥. ការបញ្ចប់ការប្រើប្រាស់

ម្ចាស់គណនី អាចលុបចោលការចូលប្រើប្រាស់សៅកម្មធនាគារចល័ត អេស ប៊ី អាយ (ខេមបូឌា) (ឬដកហូតសិទ្ធិរបស់អ្នកចុះហត្ថលេខាដើម្បីមានសិទ្ធិចូលប្រើប្រាស់គណនីរបស់ម្ចាស់គណនីតាមរយៈសៅកម្មធនាគារចល័ត អេស ប៊ី អាយ (ខេមបូឌា)) នៅពេលណាមួយក៏បាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់សាខារបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ឬបំពេញទម្រង់បែបបទវិសោធនកម្មដែលពាក់ព័ន្ធ ដើម្បីការលុបចោលហើយបញ្ជូនវាមកកាន់សាខារបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) នោះ។

ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចលុបចោល ឬព្យួរលេខកូដសម្ងាត់ លេខសម្គាល់អ្នកប្រើប្រាស់ ឬឧបករណ៍ប្រព័ន្ធសុវត្ថិភាព ដោយមិនមានការជូនដំណឹងជាមុន (លើកលែងតែមានការហាមឃាត់ដោយច្បាប់) ប្រសិនបើ៖

- ធនាគារ អេស ប៊ី អាយ (ខេមបូឌា) សង្ស័យថាម្ចាស់គណនីមានការក្លែងបន្លំ ឬការប្រព្រឹត្តអំពើខុសច្បាប់
- ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ជឿជាក់ថា ការប្រើប្រាស់លេខសម្គាល់អ្នកប្រើប្រាស់ ឬការចូលប្រើប្រាស់ដោយឧបករណ៍អេឡិចត្រូនិករបស់អ្នកម្ចាស់គណនី អាចបង្កឲ្យមានការខូចខាតដល់ម្ចាស់គណនី ឬដល់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ។
- រាល់គណនីទាំងឡាយដែលពាក់ព័ន្ធទៅនឹងលេខសម្គាល់អ្នកប្រើប្រាស់ដែលត្រូវបានបិទ
- ប្រព័ន្ធ ឬឧបករណ៍ដំណើរការរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) មានលក្ខណៈមិនប្រក្រតី ឬមិនអាចដំណើរការក្នុងការប្រើប្រាស់បាន។
- ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ជឿជាក់ថាសុវត្ថិភាពនៃការចូលប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិចរបស់ម្ចាស់គណនី ឬប្រព័ន្ធ និងឧបករណ៍ដំណើរការរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចនឹងខូច។
- ការបញ្ចូលលេខកូដសម្ងាត់មិនត្រឹមត្រូវចំនួន ០៣ (បី) ដង។
- ធនាគារ អេស ប៊ី អាយ (ខេមបូឌា) តម្រូវដោយច្បាប់ក្នុងការអនុវត្តបែបនេះ។

១៦. ការធានាសំណង

ស្ថិតក្នុងវិសាលភាពដែលច្បាប់អនុញ្ញាត ម្ចាស់គណនីយល់ព្រមផ្តល់សំណងជូនធនាគារ អេស ប៊ី អាយ (ខេមបូឌា) រាល់ការបាត់បង់ ឬការខូចខាតណាមួយ ដែលធនាគារ អេស ប៊ី អាយ (ខេមបូឌា) ទទួលរងដោយសារការអះអាងតវ៉ា ការទាមទារ ឬសកម្មភាពណាមួយដែលធ្វើឡើងបំពាននឹងធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដែលត្រូវបានកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ដោយសារតែម្ចាស់គណនី៖

- មិនបានគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្រោមលក្ខខណ្ឌទូទៅទាំងនេះ ឬ
- បានប្រព្រឹត្តកំហុសដោយធ្វេសប្រហែស ឬក្លែងបន្លំពាក់ព័ន្ធនឹងលក្ខខណ្ឌទូទៅទាំងនេះ។

១៧. ការបដ្ឋាញ្ញព័ត៌មានដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា)

ស្របតាមកាតព្វកិច្ចទូទៅរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ក្នុងការរក្សាការសម្ងាត់ចំពោះអតិថិជនរបស់ខ្លួន និងពង្រីកវិសាលភាពដែលត្រូវបានអនុញ្ញាតដោយច្បាប់ តាមរយៈការស្នើសុំ និង/ឬបន្តប្រើប្រាស់នូវសៅ

កម្មធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) លោកអ្នកយល់ព្រមថា ធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចបង្ហាញព័ត៌មានសម្ងាត់របស់លោកអ្នកបាន ជូនស្ថាប័នដូចខាងក្រោម៖

- ស្ថាប័ននិយ័តករ ភ្នាក់ងាររាជរដ្ឋាភិបាល ស្ថាប័នដែលអនុវត្តច្បាប់ និងតុលាការនៅក្នុងស្រុក។
- ធនាគារជាតិនៃកម្ពុជា ឬភាគីណាមួយដែលតម្រូវតាមច្បាប់។
- ក្រុមហ៊ុនមេ ឬក្រុមហ៊ុននៃគ្រុប ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើងខ្ញុំ សម្រាប់គោលបំណងផ្នែករដ្ឋបាល ឬប្រតិបត្តិការ។
- អ្នកផ្តល់សេវាកម្មដែលបានចូលរួមទំនាក់ទំនងដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ដើម្បីអនុវត្ត ឬជួយសម្រួលដល់មុខងារ ឬសកម្មភាពផ្សេងៗ។

ការចូលប្រើប្រាស់ព័ត៌មានរបស់លោកអ្នកដែលគ្រប់គ្រងដោយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ៖ ស្ថិតក្នុងវិសាលភាពដែលត្រូវបានអនុញ្ញាតដោយច្បាប់ លោកអ្នកអាចចូលប្រើប្រាស់ និងស្នើសុំការកែតម្រូវព័ត៌មានរបស់លោកអ្នកនៅគ្រប់ពេលវេលាបាន ដោយធ្វើការស្នើសុំផ្លាស់ប្តូរនៅគ្រប់សាខាណាមួយរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ។

១៨. ការផ្លាស់ប្តូរលក្ខខណ្ឌទូទៅ

យើងខ្ញុំអាចកែតម្រូវលក្ខខណ្ឌទូទៅនេះ តាមការសម្រេចចិត្តជាឯកត្តោភាគីបានពីពេលមួយទៅពេលមួយ ដោយមិនចាំបាច់មានការជូនដំណឹងជាមុនឡើយ។

១៩. អសន្តិភាព

១. ក្នុងករណីដែលមានភាពមិនស្របគ្នាណាមួយ រវាងលក្ខខណ្ឌទូទៅនេះ និងលក្ខខណ្ឌទូទៅដែលមាននៅលើគណនីរបស់លោកអ្នក នោះលក្ខខណ្ឌទូទៅនេះ ត្រូវយកមកអនុវត្តជំនួសចំណុចដែលមិនស្របគ្នានោះ ប្រសិនបើមិនមានការផ្តល់លក្ខខណ្ឌផ្សេងទៀតទៅក្នុងលក្ខខណ្ឌទូទៅទាំងនេះទេ។

២. ក្នុងករណីភាពមិនស្របគ្នាណាមួយ រវាងភាសាខ្មែរ និងភាសាដ៏ទៃទៀតនៃឯកសារនេះ ឯកសារជាភាសាខ្មែរ គឺយកមកអនុវត្តទៅតាមវិសាលភាពនៃចំណុចមិនស្របគ្នានោះ។

ធនាគារ អេស ប៊ី អាយ (ខេមបូឌា) រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរដោយមិនមានការជូនដំណឹងជាមុនណាមួយឡើយ។

២០. ការជូនដំណឹងក្នុងកម្មវិធី

យើងអាចធ្វើការជូនដំណឹងពី ផលិត ឬសេវាកម្មថ្មី ការផ្សព្វផ្សាយ ការធ្វើទីផ្សារ និងព័ត៌មានផ្សេងទៀតអំពី ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ទៅកាន់អ្នកតាមរយៈកម្មវិធីធនាគារចល័ត។យើងលើកទឹកចិត្តឱ្យអ្នកបើកមុខងារការជូនដំណឹងក្នុងកម្មវិធី ដូច្នេះអ្នកទទួលបានព័ត៌មានថ្មី និងការជូនដំណឹងផ្សេងទៀតដែលមាននៅក្នុងការជូនដំណឹងនៅក្នុងកម្មវិធីធនាគារចល័តរបស់យើងខ្ញុំ។

២១. ភាគព្វកិច្ចរបស់អ្នកប្រើប្រាស់

១. ប្រសិនបើគណនីរបស់លោកអ្នកគ្មានប្រតិបត្តិការចាប់ពីរយៈពេល ១២ ខែឬច្រើនជាងនេះ ចាប់ពីកាលបរិច្ឆេទនៃប្រតិបត្តិការចុងក្រោយ គណនីនោះនឹងត្រូវបានចាត់ទុកថាជា គណនីអសកម្ម។ ធនាគារមានសិទ្ធិក្នុង បិទគណនីដោយស្វ័យប្រវត្តិ ដោយមិនមានជូនដំណឹងជាមុន ប្រសិនបើមិនមានសមតុល្យក្នុងគណនី ។

២. ប្រសិនបើធនាគារឃើញថាមាន កំហុស ឬប្រតិបត្តិការណាមួយដោយអចេតនា ដែលធនាគារបានធ្វើឡើង ធនាគារមានសិទ្ធិបង្វែរប្រតិបត្តិការនេះត្រឡប់វិញ ពីគណនីរបស់លោកអ្នក។

២២. ទិន្នាន និងយន្តការដោះស្រាយ

- តើយើងខ្ញុំមានយន្តការដោះស្រាយបែបណា ប្រសិនបើលោកអ្នកមានការតវ៉ា?

យើងខ្ញុំទទួលស្គាល់ថា ពេលខ្លះអាចមានកំហុសណាមួយកើតឡើងនៅកំឡុងពេលដែលលោកអ្នកកំពុងធ្វើប្រតិបត្តិការ ឬបន្ទាប់ពីលោកអ្នកបានបញ្ចប់ប្រតិបត្តិការ ដូចជា៖ បញ្ហាប្រព័ន្ធអ៊ីនធឺណេត បញ្ហាទូរស័ព្ទដៃ កំហុសរបស់អ្នកប្រើប្រាស់ កំហុសបច្ចេកទេស/ប្រព័ន្ធ ហើយនៅពេលដែលបញ្ហាទាំងនេះកើតមានឡើង យើងខ្ញុំនឹងព្យាយាមស្វែងរកនូវមូលហេតុ និងផ្តល់នូវដំណោះស្រាយដ៏ល្អបំផុតសម្រាប់អតិថិជន។ ប្រសិនបើលោកអ្នកប្រាដកថា លោកអ្នកបានបាត់សមតុល្យ មានកំហុសបច្ចេកទេសក្នុងពេលធ្វើប្រតិបត្តិការ ឬលោកអ្នកបានបាត់ទូរស័ព្ទដៃ ឬឧបករណ៍ចល័តរបស់លោកអ្នក លោកអ្នកគប្បីទាក់ទងមកកាន់ការិយាល័យទំនាក់ទំនងអតិថិជនរបស់ធនាគារភ្លាមៗ តាមរយៈលេខទូរស័ព្ទទាក់ទង លេខ +៨៥៥ ២៣ ៩៨០ ៨៨៨ ឬ +៨៥៥ ៩៣ ៦៧១ ១១១។ ការតវ៉ា មានសុពលភាពរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃកាលបរិច្ឆេទក្នុងប្រតិទិនចាប់ពីពេលដែលកំហុសប្រតិបត្តិការ ឬបញ្ហានោះកើតមានឡើង។ ធនាគារនឹងស្រាវជ្រាវស៊ើបអង្កេតលើបញ្ហាដែលត្រូវបានតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ក្រោយពីទទួលបានការតវ៉ានោះ។ បញ្ហាភាគច្រើន ត្រូវបានដោះស្រាយបានយ៉ាងឆាប់រហ័ស និងមានភាពងាយស្រួលដោយការចូលរួមសហការជាមួយយើងខ្ញុំ។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈពេលកំណត់ខាងលើ លោកអ្នកនឹងត្រូវទទួលបានការជូនដំណឹងពីយើងខ្ញុំ អំពីមូលហេតុដែលកើតមានឡើងនេះ។

ក្នុងករណីដែលបញ្ហាទាំងនេះកើតឡើងដោយសារកំហុសរបស់ធនាគារ នោះធនាគារនឹងធ្វើការកែតម្រូវភ្លាមៗលើកំហុសនោះ និង/ឬធ្វើការកែសម្រួលកម្រៃសេវាកម្ម ឬការកែប្រែណាមួយដែលជាលទ្ធផលស្រាវជ្រាវស៊ើបអង្កេតរបស់ធនាគារ លោកអ្នកអាចធ្វើការលើកយកបញ្ហានៃការតវ៉ានោះទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ។ ធនាគារនឹងជួយគាំទ្រតាមរយៈការសម្រួលលើការផ្តល់ឯកសារពាក់ព័ន្ធ និងព័ត៌មានចាំបាច់ផ្សេងៗ។

២៣. ទិន្នានជាមួយតតិយជន

យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះលោកអ្នកឡើយសម្រាប់៖

១. រាល់អំពើវិការៈ ឬកង្វះខាតក្នុងការផ្តល់ទំនិញ និងសេវាកម្ម ដែលត្រូវទទួលបាន (ឧទាហរណ៍ដូចជា ការបញ្ចាទិញលេខកូដសម្ងាត់ PIN ចល័តតាមរយៈសេវាកម្មធនាគារចល័ត)។

២. កាលណាលោកអ្នកសម្រេចចិត្តថាលែងមានតម្រូវការលើទំនិញ ឬសេវាកម្មនោះទៀតហើយ។ លោកអ្នកត្រូវតែដោះស្រាយរ៉ាជាមួយនឹងអ្នកផ្តល់នោះ។ យើងខ្ញុំក៏មិនទទួលខុសត្រូវចំពោះការតវ៉ាណាមួយទាក់ទងនឹងទំនិញ និងសេវាកម្មរបស់អ្នកផ្តល់ឲ្យនោះ ដែលផ្តត់ផ្តង់ដល់អ្នកប្រើប្រាស់ដែរ ក្នុងករណីដែលការគិតកម្រៃទំនិញ ឬសេវានោះមានភាពត្រឹមត្រូវ។

២៤. ទំនាក់ទំនង

ប្រសិនបើអ្នកមានចម្ងល់អំពីលក្ខខណ្ឌនៃការប្រើប្រាស់ទាំងនេះ ឬលក្ខខណ្ឌផ្សេងៗរបស់កម្មវិធីធនាគារចល័ត របស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) សូមទំនាក់ទំនងមកកាន់យើងខ្ញុំតាមរយៈលេខទូរស័ព្ទ +៨៥៥ ២៣ ៩៨០ ៨៨៨ ឬ +៨៥៥ ៩៣ ៦៧១ ១១១ អ៊ីម៉ែល info@sbibank.com.kh ឬ អាសយដ្ឋាន អាគារ ២១៩ ផ្លូវ ១២៨ និង ១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ឧបសម្ព័ន្ធទី១

បញ្ជីនៃការកម្រិតទំហំប្រតិបត្តិការនៅក្នុងកម្មវិធីធនាគារចល័តរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) គិតគិតត្រឹម ខែ មិថុនា ឆ្នាំ២០២៥

ប្រតិបត្តិការផ្ទេរប្រាក់:

ប្រភេទប្រតិបត្តិការ	រូបិយប័ណ្ណ	អតិបរមាក្នុងមួយប្រតិបត្តិការ	អតិបរមាក្នុងមួយថ្ងៃ	កម្រៃសេវា
គណនីផ្ទាល់ខ្លួន	USD	១00,000	ឥតដែនកំណត់	ឥតគិតថ្លៃ
	KHR	៤00,000,000		
គណនីធនាគារ អេស ប៊ី អាយ (ខេមបូឌា) ផ្សេងទៀត	USD	១00,000	ឥតដែនកំណត់	ឥតគិតថ្លៃ
	KHR	៤00,000,000		
ទៅកាន់លេខកូដ ៩ខ្ទង់	USD	១,000	១,000	ចាប់ពី ០.៣៧៥ ដុល្លារ រហូតដល់ ២.២៥ ដុល្លារ
	KHR	៤,000,000	៤,000,000	ចាប់ពី ១,៥00 រៀល រហូតដល់ ៩,000 រៀល
	THB	៤0,000	៤0,000	ចាប់ពី ១៥ បាត រហូតដល់ ៩0 បាត
គណនីបាគង/KHQR បាគង	USD	១0,000	១0,000	ឥតគិតថ្លៃ
	KHR	៤0,000,000	៤0,000,000	
ធនាគារក្នុងស្រុក-បាគង/KHQR ធនាគារក្នុងស្រុក	USD	៥0,000	៥0,000	ឥតគិតថ្លៃ
	KHR	២00,000,000	២00,000,000	
បាគងទេសចរណ៍	USD	១0,000	១0,000	ឥតគិតថ្លៃ
	KHR	៤0,000,000	៤0,000,000	
NCS ធនាគារក្នុងស្រុក	USD	៥0,000	៥0,000	≤ ២00,000 USD និងសមមូលប្រាក់រៀល មិនគិតកម្រៃសេវា > ២00,000 USD និងសមមូលប្រាក់រៀល កម្រៃសេវា ១0 ដុល្លារ ឬ ៤0.000,00រៀល
	KHR	២00,000,000	២00,000,000	
SWIFT សេវាផ្ទេរប្រាក់ឆ្លងប្រទេស	USD	១0,000	១0,000	≤ ២00,000 USD មិនគិតកម្រៃសេវា និងកម្រៃខ្សែកាប ១៥ដុល្លារ > ២00,000 USD កម្រៃសេវា0.១២% អប្បបរិមា ១៥,00 ដុល្លារ និងកម្រៃខ្សែកាប១៥ ដុល្លារ
	USD	១,000	១,000	ឥតគិតថ្លៃ

ការទូទាត់ (វិក្កយបត្រ បញ្ចូលទឹកប្រាក់ទូរស័ព្ទ ប្រាក់កម្ចី	KHR	៤,000,000	៤,000,000
	THB	៣៤,000	៣៤,000

ឧបសម្ព័ន្ធទី២

បញ្ជីនៃសេវាកម្ម និងមុខងារសំខាន់ៗ ដែលមាននៅលើកម្មវិធីធនាគារចល័តរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)	
គណនី	ស្ថិតក្រោមមុខងាររបស់គណនីអ្នកប្រើប្រាស់អាចមើលឃើញចំពោះរាល់គណនីទាំងអស់ដែលមានជាមួយធនាគារ អេស ប៊ី អាយ (ខេមបូឌា) ហើយអាចចូលប្រើប្រាស់មុខងារ និងសេវាកម្មដូចខាងក្រោម៖ ▪ បង្ហាញគណនីទាំងអស់ ▪ បើកគណនីសន្សំថ្មីភ្លាមៗ ប្រាក់បញ្ញើនាពេលអនាគត/កំណើន ឬប្រាក់បញ្ញើមានកាលកំណត់ចល័ត ជារូបិយប័ណ្ណ ដុល្លារអាមេរិក ឬរៀល ប្រាក់បញ្ញើផ្លើស ជារូបិយប័ណ្ណ ដុល្លារអាមេរិក រៀល ឬបាត។ ▪ បង្ហាញសមតុល្យរបស់គណនី ▪ បង្ហាញស្ថានភាពទាំងស្រុងរបស់គណនី ▪ បង្ហាញ និងលាក់គណនី ▪ តាមដាន និងទាញយកប្រតិបត្តិការលម្អិតរបស់គណនីជាទម្រង់ PDF ▪ តាមដាន និងទាញយកប្រវត្តិរបាយការណ៍លម្អិតចន្លោះពេលនៃកាលបរិច្ឆេទ និងទម្រង់ផ្សេងៗគ្នា ▪ ដំណើរការគណនីអសកម្មឡើងវិញ ▪ ទាញយកវិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ដែលបានបើកនៅក្នុងកម្មវិធីធនាគារចល័ត អេស ប៊ី អាយ (ខេមបូឌា) ជាទម្រង់ PDF។
ប្រាក់បញ្ញើ	អ្នកប្រើអាចបើកគណនីប្រាក់បញ្ញើមានកាលកំណត់ ពិនិត្យមើលលម្អិតអំពីគណនីប្រាក់បញ្ញើមានកាលកំណត់ ទាញយករបាយការណ៍និងវិញ្ញាបនបត្រនៃគណនីប្រាក់បញ្ញើមានកាលកំណត់ ជ្រើសរើសគណនីប្រភេទគណនីប្រាក់បញ្ញើរបស់អ្នក។
បណ្ណ	អ្នកប្រើប្រាស់កម្មវិធីធនាគារចល័ត អេស ប៊ី អាយ (ខេមបូឌា) អាចមើលបណ្ណជាក់ស្តែង និងបណ្ណនិម្មិតរបស់ខ្លួន រួមទាំងបណ្ណ អេ ធី អឹម (ATM) បណ្ណវីសា (VISA) និងអាចចូលទៅប្រើប្រាស់មុខងារ និងសេវាកម្មពាក់ព័ន្ធដូចខាងក្រោម៖ ▪ បង្ហាញបញ្ជីនៃបណ្ណទាំងអស់ដែលអាចប្រើប្រាស់បាន ▪ បង្ហាញបណ្ណទាំងអស់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការលើគណនីដែលត្រូវបានភ្ជាប់នោះ ▪ ត្រួតពិនិត្យប្រតិបត្តិការបណ្ណលម្អិត ▪ ដាក់ដំណើរការបណ្ណថ្មីជាក់ស្តែងដែលទើបនឹងបង្កើត ▪ កំណត់លេខកូដសម្ងាត់របស់បណ្ណ ▪ បិទដំណើរការ និងដាក់ឲ្យដំណើរការឡើងវិញ ▪ បង់វិក្កយបត្រប័ណ្ណឥណទានប្រចាំខែ ▪ មើលប្រវត្តិវិក្កយបត្រប្រតិបត្តិការនៃបណ្ណឥណទាន ▪ ភ្ជាប់គណនីជាមួយប្រភេទបណ្ណពហូរបិយប័ណ្ណ

	▪ ស្នើបង្កើតបណ្ណពហរូបិយប័ណ្ណនិម្មិត ▪ មើលអត្រាប្តូរប្រាក់សម្រាប់បណ្ណពហរូបិយប័ណ្ណ ▪ ប្តូររូបិយបណ្ណសម្រាប់បណ្ណពហរូបិយប័ណ្ណ ▪ ទាញយកប្រវត្តិរបាយការណ៍លម្អិតចន្លោះពេលនៃកាលបរិច្ឆេទជាទម្រង់ PDF។
ការបើកគណនី	អ្នកប្រើប្រាស់អាចបង្កើតគណនីថ្មីសម្រាប់ គណនីសន្សំ គណនីចម្រើនតាមបំណង គណនីចម្រើនផែនការអនាគត ដែលមានរូបិយបណ្ណដូចជា ដុល្លារ រៀល និងបាត។
កម្ចី	អ្នកប្រើប្រាស់អ្នកប្រើកម្មវិធីចល័តធនាគារ អេស ប៊ី អាយ (ខេមបូឌា) អាចមើលគណនីប្រាក់កម្ចីរបស់ និងប្រើមុខងារ និងសេវាកម្មដូចជា៖ ▪ មើលគណនីប្រាក់កម្ចីទាំងអស់ ▪ មើលព័ត៌មានលម្អិតគណនីកម្ចី ▪ មើលកាលវិភាគ ឬតារាងការទូទាត់សងនៃការទូទាត់ប្រាក់កម្ចី ▪ ទាញយកប្រតិបត្តិការលម្អិតរបស់គណនីកម្ចី
គណនីប្រាក់បញ្ញើផ្លើស	អ្នកប្រើអាចបើកគណនីប្រាក់បញ្ញើមានកាលកំណត់ ពិនិត្យមើលលម្អិតអំពីគណនីប្រាក់បញ្ញើមានកាលកំណត់ ទាញយកវិញ្ញាបនប័ត្រប្រាក់បញ្ញើផ្លើសមានកាលកំណត់ ជ្រើសរើសគណនីប្រភេទគណនីប្រាក់បញ្ញើរបស់អ្នក។
ការផ្ទេរប្រាក់	អ្នកប្រើប្រាស់កម្មវិធីធនាគារចល័ត អេស ប៊ី អាយ (ខេមបូឌា) អាចធ្វើការផ្ទេរប្រាក់ជាច្រើនប្រភេទដូចខាងក្រោម ៖ ▪ គណនី អេស ប៊ី អាយ (ខេមបូឌា) ៖ ផ្ទេរប្រាក់ទៅកាន់គណនី អេស ប៊ី អាយ (ខេមបូឌា) ណាមួយ ▪ លេខកូដសម្ងាត់ចំនួន ០៩ ខ្ទង់ របស់ LHPP៖ ផ្ទេរប្រាក់ទៅកាន់លេខទូរស័ព្ទនិងដកប្រាក់តាមរយៈលេខកូដសម្ងាត់ចំនួន ០៩ខ្ទង់ នៅតាមភ្នាក់ងារ លី ហួរ រ៉េលុយ ▪ លេខទូរស័ព្ទ៖ ផ្ទេរប្រាក់ទៅកាន់លេខទូរស័ព្ទដែលភ្ជាប់ជាមួយគណនី អេស ប៊ី អាយ (ខេមបូឌា) ▪ គណនីផ្ទាល់ខ្លួន៖ ផ្ទេរប្រាក់ទៅកាន់គណនីផ្ទាល់ខ្លួន ▪ ធនាគារផ្សេងៗ-បាគង៖ ផ្ទេរប្រាក់តាមរយៈទៅកាន់ធនាគារផ្សេងៗដែលជាសមាជិកបាគង ▪ គណនីបាគង៖ ផ្ទេរប្រាក់ទៅកាន់គណនីបាគង ▪ NCS ធនាគារក្នុងស្រុក៖ ផ្ទេរប្រាក់ទៅធនាគារក្នុងស្រុកតាមរយៈប្រព័ន្ធផាត់ទាត់ជាតិ (NCS) ▪ SWIFT សេវាផ្ទេប្រាក់ឆ្លងប្រទេស៖ ផ្ញើប្រាក់ទៅក្រៅប្រទេសតាមរយៈប្រព័ន្ធ SWIFT
ការបញ្ចូលទឹកប្រាក់ទូរស័ព្ទ	អ្នកប្រើប្រាស់អាចបញ្ចូលទឹកប្រាក់ទូរស័ព្ទតាមរយៈប្រតិបត្តិការទូរគមនាគមន៍ដែលមានជាមួយនឹងគម្រោងតម្លៃជាក់លាក់ដោយប្រើលេខកូដ ឬមិនប្រើលេខកូដ។
ការទូទាត់វិក្កយបត្រ	អ្នកប្រើប្រាស់កម្មវិធីធនាគារចល័ត អាចធ្វើការទូទាត់វិក្កយបត្រ និងសេវាកម្មផ្សេងៗជាច្រើនដូចខាងក្រោម ៖ ▪ ការទូទាត់ថ្លៃទឹក និងសំរាម ▪ សេវាកម្មសាធារណៈ ▪ សេវាកម្មអចលនទ្រព្យ ▪ សេវាកម្មធានារ៉ាប់រង

	▪ ការទូទាត់កម្ចី	
ការស្នើកម្ចី	អ្នកប្រើប្រាស់អាចបំពេញពត៌មានចាំបាច់យ៉ាងឆាប់រហ័សដើម្បីស្នើសុំសម្រាប់ការប៉ាន់ប្រមាណតម្រូវការរបស់អ្នកប្រើប្រាស់តាមរយៈកម្ចីផ្សេងៗរបស់ធនាគារ។	
ការផ្តល់ជូន	អ្នកប្រើប្រាស់អាចមើលឃើញការផ្សព្វផ្សាយនិងការផ្តល់ជូនដែលទាក់ទងនឹងសេវាកម្មនិងផលិតផលរបស់ធនាគារ។	
ទីតាំងរបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា)	អ្នកប្រើប្រាស់អាចចូលទៅកាន់ផែនទីដែលបានត្រូវបានដាក់បង្ហាញ ដើម្បីស្វែងរកនូវទីតាំងសាខារបស់ធនាគារ អេស ប៊ី អាយ (ខេមបូឌា) ម៉ាស៊ីន អេ ធី អឹម និងភ្នាក់ងារ លី ហួរ រ៉េលុយ។	
ការផ្ទេរប្រាក់រហ័សនិងការទូទាត់រហ័ស	ស្ថិតក្រោមផ្នែកនេះ អ្នកប្រើប្រាស់អាចចូលប្រើប្រាស់គំរូដែលបានរក្សាទុកស្រាប់របស់អ្នកទទួល និងសេវាកម្មផ្តល់ ឬបង្កើតគំរូថ្មីសម្រាប់ការទូទាត់ និងផ្ទេរប្រាក់រហ័សបានយ៉ាងងាយស្រួល។	
QR ស្កេន	ជាមួយនឹងមុខងារ QR ស្កេន អ្នកប្រើប្រាស់អាចស្កេន QR ដើម្បីដំណើរការប្រតិបត្តិការបានដូចខាងក្រោម ៖ ▪ បង់ប្រាក់ជាមួយនឹង QR នៅតាមហាងទំនិញដែលមានទទួលបង់តាមរយៈ អេស ប៊ី អាយ (ខេមបូឌា) ឬ បាគង។ ▪ ការផ្ទេរប្រាក់ពីគណនីមួយទៅកាន់គណនីមួយទៀតដោយប្រើ KHQR។	
ទំព័រដើម	**ប្រវត្តិរូបរបស់ខ្ញុំ**	អ្នកប្រើប្រាស់អាចមើលលេខទូរស័ព្ទដែលបានចុះឈ្មោះ ឈ្មោះពេញ និងអាសយដ្ឋានអ៊ីមែលដែលបានរក្សាទុកជាមួយធនាគារ ឬធ្វើបច្ចុប្បន្នភាពរូបភាព។
	ការទំនាក់ទំនង	អ្នកប្រើប្រាស់អាចទំនាក់ទំនងមកកាន់ការិយាល័យសេវាកម្មអតិថិជនរបស់ធនាគារ អេស ប៊ី អាយ ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ក្នុងមួយថ្ងៃ និង ០៧ (ប្រាំពីរ) ថ្ងៃ ក្នុងមួយសប្តាហ៍តាមរយៈ សារ Messenger សារ Telegram ឬការហៅចូលមកកាន់លេខ Hotline របស់យើងខ្ញុំ។
	ការកំណត់ផ្សេងៗ	អ្នកប្រើប្រាស់អាចមើលព័ត៌មានផ្ទាល់ខ្លួន និងគ្រប់គ្រងការកំណត់ផ្សេងៗទៀតនៅក្នុងកម្មវិធី ដូចជាការផ្លាស់ប្តូរលេខកូដសម្ងាត់ និងបើកឲ្យដំណើរការមុខងារកំណត់អត្តសញ្ញាណផ្ទៃមុខជាដើម។